# របាយការណ៍អ្នកឃ្លាំមើលតុលាការកាត់ទោសខ្មែរក្រហម


កម្មវិធីរបស់ The Asian International Justice Initiative

ឆ្នាំទី១ លេខ ១៨ សប្តាហ៍ទី១៨ (២៤-២៧ សីហា ឆ្នាំ២០០៩)


## "សវនាការអង្គសេចក្តីលើករណីអតីតប្រធានមន្ទីរ ស-២១ កាំង ហ្គិចអាវ ហៅ ឌុច"



*រូបភាព : លោក កាំង ហ្គិចអ៊ាវ ហៅ ឌុច ក្នុងបន្ទប់សវនាការ (អតីតប្រធានមន្ទីរ ស-២១)*

## ១. សេចក្តីសង្ខេប

*"បាចអង្កាមបញ្ច្រាស់ខ្យល់នឹងទទួលផលអាក្រក់មិនខាន ។ អង្គជំនុំជម្រះបានសួរដេញដោល ថាតើគប្បីអនុញ្ញាតឱ្យមេធាវីដើមបណ្តឹងរដ្ឋប្បវេណីដើរតួរជាព្រះរាជអាជ្ញា..." ។*

តួនាទីភាគីដើមបណ្តឹងរដ្ឋប្បវេណីបានក្លាយជាចំណុចសំខាន់នាសប្តាហ៍នេះ ខណៈដែលមេធាវីតំណាង និងមេធាវីការពារក្តីបានពិភាក្សាតទល់ ស្តីពីបញ្ហាច្បាប់ពាក់ព័ន្ធនឹងភាគីដើមបណ្តឹងរដ្ឋប្បវេណី ។ នៅក្នុងបរិបទរបស់ អ.វ.ក.ត ភាគីដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិចូលរួមក្នុងកិច្ចដំណើរការក្តីនៃបទឧក្រិដ្ឋកម្មអន្តរជាតិ អង្គជំនុំជម្រះបានចេញសេចក្តីសម្រេចសំខាន់មួយ ស្តីពីយុត្តាធិការរបស់ អ.វ.ក.ត ។ នៅទីបំផុត ការប្រកាសមួយលើកឡើងថា ភាគីដើមបណ្តឹងរដ្ឋប្បវេណីមិនមានតួនាទីក្នុងការដាក់ទោសទណ្ឌដល់ជនជាប់ចោទឡើយ ហើយមេធាវីតំណាងក៏មិនមានសិទ្ធិសួរដេញដោលជនជាប់ចោទ និងសាក្សីលើប្រធានបទ ស្តីពីអត្តចរិកជនជាប់ចោទដែរ ។

## ២. បញ្ហាច្បាប់ និងនីតិវិធី

### ក. សេចក្តីសង្ខេបនៃសក្ខីកម្ម

នាសប្តាហ៍នេះ សេចក្តីសង្ខេបលម្អិតពីសក្ខីកម្មពាក់ព័ន្ធនឹងការប្តឹងទាមទាររបស់ដើមបណ្តឹងរដ្ឋប្បវេណី :

- លោកស្រី **ជុំ នៅ** (ដើមបណ្តឹងរដ្ឋប្បវេណីក្រុម២) ។ លោកស្រីបានរៀបរាប់ពីប្រវត្តិទុក្ខសោក ស្តីពីការបាត់បង់កូននៅមន្ទីរឃុំឃាំងព្រៃស និងស្វាមីត្រូវសម្លាប់នៅមន្ទីរ ស-២១ ។

- លោកស្រី **ជិន ណាវី** (ដើមបណ្តឹងរដ្ឋប្បវេណីក្រុម២) ។ ប្តីលោកស្រីត្រូវចាប់ខ្លួន និងសម្លាប់នៅមន្ទីរ ស-២១ ។

- លោក **ទូច មុន្និន** (ដើមបណ្តឹងរដ្ឋប្បវេណីក្រុម៤) ។ លោកបានអះអាងថា ប្អូនជីដូនមួយឈ្មោះ **ជា ខន** ត្រូវបានឃុំឃាំង និង សម្លាប់នៅមន្ទីរ ស-២១ ។

ក្នុងនាមជាជនរងគ្រោះផ្ទាល់ ជាស្ត្រីមានផ្ទៃពោះ និងជាម្តាយនៅមន្ទីរ ស-២១ លោកស្រី **ជុំ នៅ** បានរៀបរាប់ពីព្រឹត្តការណ៍សំខាន់ៗពាក់ព័ន្ធនឹងស្ថានភាពនៅគុកព្រៃស និងការប្រឈមមុខជាមួយជនជាប់ចោទ ដែលជនជាប់ចោទបានយកកាំភ្លើងភ្ជង់ក្បាលគាត់ ប៉ុន្តែ **ឌុច** បានបដិសេធចោលនូវសក្ខីកម្មនេះ ។ លោកស្រី **ជុំ នៅ** ជាអតីតយុទ្ធនារីខ្មែរក្រហមបានលាតត្រដាងអំពីទស្សនៈវិស័យក្នុងនាមជនរងគ្រោះ ហើយក៏ជាជនល្មើសនៅសម័យនោះ ។

## សក្ខីកម្មពាក់ព័ន្ធនឹងអត្តចរិកជនជាប់ចោទ

នៅថ្ងៃព្រហស្បតិ៍ អង្គជំនុំជម្រះបានចាប់ផ្តើមស្តាប់សក្ខីកម្មពាក់ព័ន្ធនឹងអត្តចរិកជនជាប់ចោទ ។ ជនជាប់ចោទបានបរិយាយយ៉ាងលម្អិតពីព្រឹត្តការណ៍នានា ដែលមានក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងជំនុំជម្រះ ព្រមទាំងឆ្លុះបញ្ចាំងឱ្យឃើញនូវឥទ្ធិពលមនោគមវិជ្ជា និងការតាំងចិត្តរបស់ខ្លួន ។ សក្ខីកម្ម និងជំហរជនជាប់ចោទនៅតែស៊ីសង្វាក់គ្នា ដោយសារការតក់ស្លុតរបស់គាត់នៅឆ្នាំ១៩៧៥ ទើបធ្វើឱ្យគាត់មានការស្ទាក់ស្ទើរក្នុងការអនុវត្តន៍ការងារ ក្នុងនាមជាប្រធានមន្ទីរ ស-២១ ប៉ុន្តែគ្មានជម្រើសត្រូវតែបង្ខំចិត្តធ្វើ បើពុំដូច្នោះទេនឹងត្រូវគេកំទេច ។

### ខ. បញ្ហាច្បាប់លើកឡើងកំឡុងសវនាការ

ការតាំងសំណួរបច្ចេកទេសច្បាប់ត្រូវបានដាក់ចំពោះមុខអង្គជំនុំជម្រះ កំឡុងសវនាការនាសប្តាហ៍នេះ មេធាវីតំណាង និងមេធាវីការពារក្តីបានពិភាក្សាតទល់គ្នា ស្តីពីការទទួលយកពាក្យសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។

***ការតវ៉ានឹងការទទួលយកពាក្យសុំដើមបណ្តឹងរដ្ឋប្បវេណីនៅតំណាក់កាលនេះ :*** នៅរសៀលថ្ងៃអង្គារ មេធាវីតំណាងបានលើកឡើងដំបូងនូវទល្ហីករណ៍ប្រឆាំងនឹងមេធាវីការពារក្តី អំពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនាពេលនេះ ។ ផ្អែកតាមវិធាន ២៣(៤) និងវិធាន ៨៣(១) នៃវិធានផ្ទៃក្នុង មេធាវីដើមតំណាងបានប្រកាសថា ការសួរដេញដោលចំពោះភាពអាចទទួលយកបាននូវពាក្យស្នើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណីមិនគួរហួសពីសវនាការបឋម ដែលបានរៀបចំកាលពីថ្ងៃទី១៨-១៩ ខែកុម្ភៈ ឆ្នាំ២០០៩ ឡើយ ។ វិធាន ១០០(១) បានអនុញ្ញាតឱ្យអង្គជំនុំជម្រះអាចសម្រេចទទួលយកពាក្យសុំដើមបណ្តឹងរដ្ឋប្បវេណីនៅគ្រប់ដំណាក់កាលនៃកិច្ចនីតិវិធី ប៉ុន្តែភាពផ្ទុយគ្នាបានស្តែងឡើងរវាងសិទ្ធិរបស់អង្គជំនុំជម្រះក្នុងការសម្រេចអំពីភាពអាចទទួលយកបាន និងសិទ្ធិមេធាវីការពារក្តីក្នុងការជំទាស់ ។

ទល្លីករណ៏បឋមរបស់មេធាវីការពារក្តីក្នុងការឆ្លើយតប គឺការជំទាស់ត្រូវអនុញ្ញាតឱ្យធ្វើបាន យោងតាមសំណើរបស់អង្គជំនុំជម្រះ ។ វិធាន ១០០(១) បានអនុញ្ញាតឱ្យអង្គជំនុំជម្រះសម្រេចអំពីភាពអាចទទួលយកបានពាក្យសុំដើមបណ្តឹងរដ្ឋប្បវេណីដោយមិនរឹតបន្តឹងពេលវេលា គួរសង្កេតថា មេធាវីការពារក្តីបានប្រើសិទ្ធិក្នុងការលើកឡើងនូវការជំទាស់របស់ខ្លួន ចំពោះភាពអាចទទួលយកបាននៃពាក្យសុំ នៅពេលអង្គជំនុំជម្រះបានផ្តល់ឱកាសឱ្យធ្វើការសង្កេត ដើម្បីជំនួយដល់សេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ។ ចំណុចសំខាន់មួយទៀតនៃការឆ្លើយតបរបស់មេធាវីការពារក្តី ខ្លួនមិនរំពឹងថា នឹងលើកឡើងនូវការជំទាស់ទាំងអស់តាំងពីដំណាក់កាលដំបូង ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណីបន្តការផ្តល់ភស្តុតាងគាំទ្រលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីជាហូរហែររហូតមកដំណាក់កាលនេះ ។

***តំរូវឱ្យមានភស្តុតាងបន្ថែមគាំទ្រពាក្យសុំដើមបណ្តឹងរដ្ឋប្បវេណី :*** ការពិភាក្សាតទល់ធ្វើឡើងដោយមេធាវីការពារក្តីចំពោះពាក្យសុំដើមបណ្តឹងរដ្ឋប្បវេណីផ្អែកលើមូលដ្ឋានថា ដើមបណ្តឹងរដ្ឋប្បវេណីខ្លះមិនបានផ្តល់ភស្តុតាងជាឯកសារ ដើម្បីបង្ហាញនូវទំនាក់ទំនងជាមួយជនរងគ្រោះ ដែលបានអះអាងថា ជាប់ឃុំឃាំងនៅមន្ទីរ ស-២១ ។

នៅថ្ងៃពុធ ឆ្លើយតបនឹងការលើកឡើងនេះ ក្រុមមេធាវីតំណាងបានតវ៉ាថា មិនមានការកំណត់ជាក់លាក់ណាមួយទាក់ទងនឹងភស្តុតាងទេ ហើយពាក្យសុំដើមបណ្តឹងរដ្ឋប្បវេណីមិនគួរឱ្យបង្ហាញភស្តុតាងភ្ជាប់ជាមួយនោះដែរ ។ ជាងនេះទៀត ឯកសារនៅមន្ទីរ ស-២១ មិនមានភាពគ្រប់គ្រាន់ ដោយសារកន្លងទៅជាង ៣០ឆ្នាំហើយ ចំណែកឯកសារ រូបថត ប្រវត្តិរូប សង្ខេបចម្លើយសារភាព និងបញ្ជីឈ្មោះអ្នកទោស ដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវជាក់លាក់ថា ជនរងគ្រោះបានជាប់ឃុំនៅមន្ទីរ ស-២១ ។

***ទំនាក់ទំនងរវាងពាក្យសុំដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះនៅមន្ទីរ ស-២១ :*** ការជំទាស់របស់មេធាវីការពារក្តីមានលក្ខណៈសមស្របទាក់ទងនឹងទំនាក់ទំនងញាតិរវាងដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះនៅមន្ទីរ ស-២១ មានចែងក្នុងវិធានផ្ទៃក្នុង ។ នៅថ្ងៃពុធ ដោយសារទំនាក់ទំនងញាតិត្រូវបានកំណត់ ទើបគ្រប់ពាក្យសុំត្រូវសួរដេញដោលចំពោះមុខអង្គជំនុំជម្រះ ។ ចំណែកឯពាក្យសុំដើមបណ្តឹងរដ្ឋប្បវេណី **E2-22** អតីតទាហានខ្មែរក្រហមអះអាងថា គាត់ជាសាក្សីបានឃើញផ្ទាល់ភ្នែកការចាប់មិត្តភ័ក្រ្តជិតស្និតខ្លួន ៦នាក់ ដាក់ឃុំឃាំង និងសម្លាប់នៅមន្ទីរ ស-២១ ។

មេធាវីការពារក្តីអះអាងថា ការបាត់បង់ទំនាក់ទំនងខ្សែញាតិនាំឱ្យពាក្យសុំពុំមានសុពលភាព និងមិនអាចទទួលយកបាន ។ ជាការឆ្លើយតប លោកស្រី **Fabienne Trusse-Napouse** ជាមេធាវីតំណាង **E2-22** បានស្នើសុំតុលាការឱ្យចេញសេចក្តីសម្រេចលើអង្គហេតុដែលពាក់ព័ន្ធ ។

## ៣. ការចូលរួមរបស់ជនរងគ្រោះ និងសាក្សី និងការការពារ និងគាំពារជនរងគ្រោះ

***វត្តមានដើមបណ្តឹងរដ្ឋប្បវេណី :*** ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១០រូប មានវត្តមាននៅក្នុងសវនាការ នៅថ្ងៃច័ន្ទ និងអង្គារ ។ ចំណែកឯនៅថ្ងៃពុធ និងព្រហស្បត្តិ៍ មានចំនួនតែ ៩រូប ។

***វត្តមានមេធាវីតំណាង ៖*** មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម២ លោកស្រី **Silke Studzinsky** ចូលសម្រាក់នៅមន្ទីរពេទ្យ ដោយអវត្តមានពីកិច្ចនីតិវិធី នាសប្តាហ៍នេះ ។ តាមការប៉ាន់ស្មាន ស្ថានភាពជំងឺអាចធ្វើឱ្យលោកស្រីមិនអាចចូលរួមកិច្ចនីតិវិធីមួយរយៈ មេធាវីតំណាងក្រុមផ្សេងបានផ្តល់ការគាំទ្រ និងជួយសម្រួលកំឡុងពេលអវត្តមានលោកស្រី ។ មេធាវីតំណាងក្រុម២ និងក្រុម៤ លោក **ហុង គីមសួន** ក៏អវត្តមាន នៅថ្ងៃពុធ ចំណែកមេធាវី **គង់ ពិសី** តំណាងក្រុម៣ អវត្តមាននៅ ថ្ងៃព្រហស្បតិ៍ ។

***ការជំទាស់លើពាក្យសុំដើមបណ្តឹងរដ្ឋប្បវេណី ៖*** ការពិភាក្សាស្តីពីពាក្យសុំដើមបណ្តឹងរដ្ឋប្បវេណី បានលើកឡើងតាមកាលវិភាគបម្រុងទុក ពីរសៀលថ្ងៃអង្គារ រហូតព្រឹកថ្ងៃព្រហស្បតិ៍ ។

ការជំទាស់លើពាក្យសុំដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២រូប គឺ **D25-20** និង **E2-57** នៅថ្ងៃពុធ មេធាវីការពារក្តីបានដកការជំទាស់ខ្លួនវិញ ដោយសារមានឯកសារថ្មីបញ្ជាក់ពីមូលដ្ឋានគ្រឹះនៃពាក្យសុំ ។

ដើមបណ្តឹងរដ្ឋប្បវេណី **E2-77**, **E2-49** និង **E2-88** បានបោះបង់សិទ្ធិជាដើមបណ្តឹងរដ្ឋប្បវេណី ស្របតាមវិធាន ២៣ (១០) នៃវិធានផ្ទៃក្នុង ។

***ការម្រេចមិនឱ្យមេធាវីតំណាងមានសិទ្ធិលើកឡើងពីការដាក់ទោសទណ្ឌ ៖*** នៅថ្ងៃព្រហស្បតិ៍ ចាប់ផ្តើមកិច្ចនីតិវិធីសេចក្តីសម្រេចមួយត្រូវបានប្រកាសថា មេធាវីតំណាងមិនមានសិទ្ធិលើកឡើងពីការដាក់ទោសទណ្ឌ តាមការធ្វើសេចក្តីសន្និដ្ឋានខ្លួនឡើយ ។ នៅថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០០៩ ដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ និងក្រុម២ បានដាក់ការស្នើសុំសិទ្ធិរបស់ខ្លួន ។ នៅទីបញ្ចប់ដំណោះស្រាយបញ្ហានេះ អង្គជំនុំជម្រះបានបដិសេធលើសំណើសុំនោះ ដោយលោកចៅក្រម **Lavergne** បានលើកឡើងពីការខ្វែងគំនិតគ្នា ។ សេចក្តីសម្រេចជាលាយលក្ខអក្សរ និងហេតុផលនៃការសម្រេចនេះត្រូវយកតាមសម្លេងភាគច្រើន ហើយសម្លេងភាគតិចទុកជាមូលដ្ឋាន ។

ភាគីដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានណែនាំមិនឱ្យលើកឡើងពីទោសទណ្ឌ រួមមាន ១-ការដាក់កម្រិតទោសទណ្ឌ ២-ការដាក់សេចក្តីសន្និដ្ឋានពាក់ព័ន្ធនឹងទោសទណ្ឌ ៣-ការដាក់ការវាយតម្លៃលើអង្គហេតុស្ថិតក្រោមការសម្រេចទោសទណ្ឌ ។ ទោះបីយ៉ាងណា មេធាវីតំណាងអាចអនុញ្ញាតឱ្យលើកឡើងនូវអង្គហេតុមួយ នៅពេលនិយាយយោងលើកំហុសចេតនា ឬអចេតនារបស់ជនជាប់ចោទ ឬការទាមទារសំណងការខូចខាត និងជំងឺចិត្ត ។

***ការសម្រេចមិនឱ្យមេធាវីតំណាងសួរដេញដោលជនជាប់ចោទ និងសាក្សីពាក់ព័ន្ធនឹងអត្តចរិកជនជាប់ចោទ ៖*** បញ្ហានេះក៏បានប្រកាសឱ្យដឹងនៅថ្ងៃព្រហស្បតិ៍ បញ្ជាក់ពីការកម្រិតសិទ្ធិផ្សេងទៀតលើតួនាទីភាគីដើមបណ្តឹងរដ្ឋប្បវេណី ។ តាមការប្រកាសសេចក្តីសម្រេចរបស់ប្រធានអង្គជំនុំជម្រះបានឱ្យដឹងថា ការដាក់សេចក្តីសន្និដ្ឋានផ្ទាល់មាត់លើសិទ្ធិតាំងសំណួរទៅកាន់ជនជាប់ចោទ និងសាក្សី ស្តីពីអត្តចរិកជនជាប់ចោទ គ្រប់ភាគីរួមទាំងសហព្រះរាជអាជ្ញាត្រូវកំណត់ទិសដៅដោយអង្គជំនុំជម្រះចំពោះការដាក់សេចក្តីសន្និដ្ឋានខ្លួន ។ គួរកត់សម្គាល់ អង្គជំនុំជម្រះបានស្នើថា គ្រប់ភាគីគួរអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវសេចក្តីសម្រេចពាក់ព័ន្ធនឹងទោសទណ្ឌនៅពេលធ្វើសេចក្តីសន្និដ្ឋាន ។

ពាក់ព័ន្ធនឹងការតវ៉ាលើកឡើងដោយសហព្រះរាជអាជ្ញា និងមេធាវីតំណាងអំពីសិទ្ធិចូលរួមក្នុងការផ្តល់យោបល់ ជាគោលការណ៍ យោងតាមច្បាប់វិធានផ្ទៃក្នុង ភាគីដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិពេញលេញក្នុងនីតិវិធី មានសិទ្ធិចូលរួមនៅគ្រប់តំណាក់កាលនៃសវនាការ ។ តាមការបារម្ភពីពេលវេលា ការកំណត់មួយបានលើកឡើងថា ការតំណាងមិនគួរធ្វើឱ្យខូចកំណត់ទុកទេ កន្លងមក មេធាវីតំណាងបានចូលរួមសួរដេញដោលគ្រប់អង្គហេតុទាំងអស់ចំពោះមុខអង្គជំនុំជម្រះ ។ ជាងនេះទៀត គ្មានការជំទាស់ណាមួយលើកឡើង នៅពេលមេធាវីតំណាងតាំងសំណួរពាក់ព័ន្ធនឹងអត្តចរិកជនជាប់ចោទ ។ ភាពខុសប្លែកគ្នារវាងសាក្សីជំនាញ និងសាក្សីធម្មតា ក្នុងការផ្តល់សក្ខីកម្មចំពោះអង្គហេតុតែមួយ គឺមិនអាចទៅរួចទេ *"តាមការអនុវត្តប្រព័ន្ធច្បាប់ស៊ីវិល"* ។ បន្ថែមលើនេះ ការទទួលស្គាល់ពីអង្គហេតុពាក់ព័ន្ធអត្តចរិកជនជាប់ចោទ គឺអាចជាការដាក់ទោសទណ្ឌ ដែលអង្គជំនុំជម្រះបានសម្រេចមិនអនុញ្ញាឱ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើការលើកឡើង ។ សហព្រះរាជអាជ្ញាបានដាក់ការសន្និដ្ឋានពាក់ព័ន្ធនឹងកំហុសជនជាប់ចោទ ។

***ការពិភាក្សាដ៏តានតឹងចំពោះការចូលរួមរបស់ជនរងគ្រោះ :*** នាសប្តាហ៍នេះ ភាពតានតឹងបានកើតឡើងចំពោះការចូលរួមរបស់ជនរងគ្រោះ ។ មេធាវីតំណាង និងសហព្រះរាជាអាជ្ញា បានលើកវិធាន ២៣ នៃវិធានផ្ទៃក្នុង បំណងជំរុញឱ្យភាគីដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិ ក្នុងនាមជាភាគីមួយក្នុងរឿងក្តី ចំណែកឯមេធាវីការពារក្តីបានលើកឡើងពីកង្វល់ទាក់ទងនឹងការកម្រិតសិទ្ធិចូលរួមរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី ។

ការលើកនូវអំណះអំណាងពីសិទ្ធិដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការដេញដោលពីអត្តចរិកជនជាប់ចោទ សហព្រះរាជាអាជ្ញាអន្តរជាតិ ចង្អុលបង្ហាញយ៉ាងច្បាស់ថា ដើមបណ្តឹងរដ្ឋប្បវេណី គឺជាភាគីមួយក្នុងសវនាការអាចមានសិទ្ធិចោទសួរជនជាប់ចោទ ។ យោងតាមវិធាន ២១(១) សេចក្តីសម្រេចបន្ថយសិទ្ធិភាគីដើមបណ្តឹងរដ្ឋប្បវេណី គឺមិនសមស្របទេ ។ ការលើកឡើងរបស់សហព្រះរាជអាជ្ញាបន្តថា ការចូលរួមរបស់ជនរងគ្រោះ គឺត្រឹមត្រូវ ព្រោះធ្វើឱ្យយល់ឱ្យកាន់តែច្បាស់ពីទស្សនៈជនរងគ្រោះ ។

***ការលើកឡើងអង្គហេតុថ្មីចំពោះមុខអង្គជំនុំជម្រះ :*** នៅថ្ងៃព្រហស្បតិ៍ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីលោក **ហុង គឹងសួន** បានដាក់សំណើសុំអនុញ្ញាតបង្ហាញភស្តុតាងថ្មីទាក់ទងនឹងដើបណ្តឹងរដ្ឋប្បវេណី **E2-32** ។ ដើមបណ្តឹង **E2-32** មិនបានលើកភស្តុងតាងនេះកំឡុងសក្ខីកម្មខ្លួនកាលពីខែកក្កដា ឆ្នាំ២០០៩ ដែលថា លោកស្រីត្រូវបានអតីតអ្នកយាមមន្ទីរ ស-២១ រំលោភ ។ បន្ទាប់ពីអង្គជំនុំជម្រះមិនយល់នូវខ្លឹមសារសំណើផ្ទាល់មាត់នេះ មេធាវី **ហុង គឹមសួន** បានបញ្ជាក់ថា សូមផ្តល់ភស្តុតាងនេះជាសំណេរវិញ ។

វិធាន ៨៧ (៤) បានអនុញ្ញាតឱ្យមានការលើកឡើងនូវអង្គហេតុថ្មី ភាគីស្នើសុំត្រូវបង្ហាញ និងពន្យល់ដល់អង្គជំនុំជម្រះពីមូលហេតុដែលខ្លួនមិនមានលទ្ធភាពបង្ហាញភស្តុតាងតាំងពីដំបូង ។ ទោះបីជាមានការស្មុគស្មាញក្នុងការលើកឡើងភស្តុតាងក្រោយរបស់ដើមបណ្តឹងរដ្ឋប្បវេណី មេធាវីការពារក្តីលោក **Roux** បានជំទាស់ថា បញ្ហានេះមិនសមស្របលើកក្នុងពេលនេះទេ ។ ប៉ុន្តែលោក **ហុង គឹមសួន** លើកឡើងថា លោកស្រី **Silke Studzinsky** មេធាវីតំណាង **E2-32** បានស្នើបញ្ហានេះជាមុនរួចហើយ ។ អង្គជំនុំជម្រះសម្រេច លើកយកបញ្ហានេះទៅធ្វើសេចក្តីសម្រេចពេលក្រោយ ។

***បទដ្ឋាន/ស្តង់ដារមរៀបចំដើមបណ្តឹងរដ្ឋប្បវេណី :*** នៅថ្ងៃចន្ទ សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី **ជិន ណារី** និង **តូច មុន្និន** បានចាកឆ្ងាយពីអង្គហេតុនៃសំណុំរឿងក្តី០០១ ។ ប៉ុន្តែមេធាវី **គង់ ពិសី** និងមេធាវី **ហុង គីមសួន** មិនបានតម្រង់ទិសឱ្យពួកគេផ្តល់សក្ខីកម្មអំពីអង្គហេតុដែលពាក់ព័ន្ធ ។ គួររំលឹកថា អង្គជំនុំជម្រះបានបញ្ជាក់យ៉ាងច្បាស់ អំពីការផ្តល់ឱកាសឱ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើសេចក្តីថ្លែងតាមការចង្អុលបង្ហាញរបស់មេធាវីខ្លួន ជាពិសេស ជួយណែនាំកូនក្តីឱ្យផ្តល់សក្ខីកម្មលើអង្គហេតុពាក់ព័ន្ធ និងគួរគប្បីបង្អាក់កូនក្តី នៅពេលនិយាយចាកឆ្ងាយប្រធានបទ ។ សក្ខីកម្មលោកស្រី **ជិន ណារី** បានអូសបន្លាយពេលយ៉ាងយូរ ហើយមិនជាប់ពាក់ព័ន្ធអង្គហេតុ ធ្វើឱ្យលោក **តូច មុន្និន** សល់ពេលតិចតួចក្នុងការផ្តល់សក្ខីកម្មខ្លួន ព្រមទាំងធ្វើឱ្យសវនាការចប់យឺតជាងម៉ោងកំណត់ ។ បញ្ហានេះ ជាឧទាហរណ៍មួយបង្ហាញពីកង្វះបទដ្ឋាន/ស្តង់ដារមរៀបចំដើមបណ្តឹងរដ្ឋប្បវេណី ។ ម្យ៉ាងទៀត ធ្វើឱ្យសម្លេងជនរងគ្រោះក្នុងដំណើរការនីតិវិធីចុះខ្សោយពុំមានតម្លៃ និងបន្ថយល្បឿនកិច្ចដំណើការនីតិវិធី ។

## ៤. ការគ្រប់គ្រងសវនាការ

***ការគ្រប់គ្រងតុលាការ :*** នាសបាហ៍នេះ ដំណើរការនីតិវិធីបានបញ្ចប់តាមកាលកំណត់ ទោះបីជាមានបញ្ហា មានការជជែកពិភាក្សា និងដោះស្រាយជាច្រើនក៏ដោយ ។ អង្គជំនុំជម្រះទទួលជោគជ័យក្នុងការធានាឱ្យឆាប់រហ័សនៃដំណើរការនីតិវិធី ។

នៅថ្ងៃចន្ទ ដំណើការនីតិវិធីត្រូវសម្រាក់យឺតជាងធម្មតា ដើម្បីបញ្ចប់ការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣តាមការគ្រោងទុក ។ ដើមបណ្តឹងរដ្ឋប្បវេណីដំបូង ២រូប បានប្រើពេលច្រើន និងផ្តល់សក្ខីកម្មមិនពាក់ព័ន្ធអង្គហេតុ ដែលធ្វើឱ្យលោក **តូច មុន្និន** ដើមបណ្តឹងរដ្ឋប្បវេណីចុងក្រោយមានពេលតិចតួចក្នុងការចោទសួរជនជាប់ចោទ ។ ទោះបីជាអង្គជំនុំជម្រះបានផ្តល់វេទិការឱ្យមេធាវីដើមបណ្តឹងរដ្ឋប្បវេណីគ្រប់គ្រងការធ្វើសក្ខីកម្មកូនក្តីខ្លួនក៏ដោយ ក្រុមឃ្លាំមើលយល់ថា អង្គជំនុំជម្រះគួតែធ្វើអន្តរាគមន៍លើករណីនេះ ។

នៅថ្ងៃអង្គារ និងថ្ងៃពុធ អង្គជំនុំជម្រះបានសម្រាក់មុនកាលកំណត់ ដើម្បីរៀបចំកិច្ចប្រជុំផ្ទៃក្នុងពិភាក្សាពីបញ្ហាបន្ទាន់បង្ហំទាក់ទងនឹងការរៀបចំនីតិវិធីដើម្បីចោទសួរពីអត្តចរិកជនជាប់ចោទ ។ នៅថ្ងៃពុធ និងថ្ងៃព្រហស្បត្តិ៍ ភាគីបានលើកឡើងពីអំណះអំណាងមិនសមស្របក្នុងការបញ្ចប់ការសន្និដ្ឋានខ្លួន ដែលហាក់ងាកចេញពីកាលកំណត់ ។ ប្រធានអង្គជំនុំជម្រះ **និល ណុន** បានប្រឹងប្រែងដ៏គួរឱ្យកោតសរសើរក្នុងការបញ្ឈប់មិនឱ្យមានការជជែកដេញដោលតទៅទៀត ។

***ការដកសិទ្ធិដើមបណ្តឹងរដ្ឋប្បវេណីនៅតំណាក់ចុងក្រោយនៃកិច្ចនីតិវិធី :*** ស្ថិតក្រោមបញ្ហាបច្ចេកទេស ថាតើមេធាវីការពារក្តីមានសិទ្ធិជំទាស់ការទទួលយកពាក្យសុំដើមបណ្តឹរដ្ឋប្បវេណីនៅដំណាក់កាលចុងក្រោយនៃកិច្ចនីតិវិធី ។ សម្រាប់រយៈពេល ៧ខែ កន្លងទៅនេះ ចាប់ពីសវនាការដំបូង ដើមបណ្តឹងរដ្ឋប្បវេណីមានជំនឿចិត្តយ៉ាងមុតមាំលើសកម្មភាពខ្លួន ទោះបីជា មានបញ្ហាក្នុងការចំណាយលើការធ្វើដំណើរទៅតុលាការកំឡុងផ្តល់សក្ខីកម្មរបស់ខ្លួន ។ នៅដំណាក់កាលចុងក្រោយនៃកិច្ចនីតិវិធី ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានដកសិទ្ធិ ដែលជាព្រឹត្តការណ៍ដ៏សោកសៅមួយសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី ។ *"ការទទួលស្គាល់ជាបណ្តោះអាសន្ន"* របស់អង្គជំនុំជម្រះលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អាចត្រូវដោះស្រាយដោយវិធាននៃផ្ទៃក្នុង ដែលថ្លែងពីការទទួលយកពាក្យសុំនៅដំណាក់ចុងក្រោយនៃកិច្ចនីតិវិធី និងការលើកឡើងនូវការពិភាក្សាលើជាពាក្យសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។

***កាលបរិច្ឆេទកំណត់ការដាក់ឯកសារគាំទ្រពាក្យសុំដើមបណ្តឹងរដ្ឋប្បវេណី :*** នៅព្រឹកថ្ងៃព្រហស្បតិ៍ សហព្រះរាជអាជ្ញាអន្តរជាតិស្នើសុំថា អង្គជំនុំជម្រះបានទទួលស្គាល់ពេលម៉ោងកំណត់សម្រាប់ភាគីក្នុងការសួរដេញដោលជនជាប់ចោទពាក់ព័ន្ធនឹងអត្តរិក ។ ជាគោលការណ៍ យ៉ាងតិចរយៈពេល ១ម៉ោង ឬ ១ម៉ោងកន្លះ សម្រាប់ភាគីក្នុងការសួរដេញដោល ។ សហព្រះរាជអាជ្ញាសង្កត់ធ្ងន់ថា រយៈពេលចុងក្រោយក្នុងការសួរដេញដោលជនជាប់ចោទពាក់ព័ន្ធនឹងអត្តចរិក និងការទទួលខុសត្រូវរបស់ជនជាប់ចោទ គួរផ្តល់ឱ្យបានសមស្រប ។ សេចក្តីសម្រេចលើការស្នើសុំនេះ ត្រូវបានពន្យាទៅថ្ងៃព្រហស្បតិ៍ អង្គជំនុំជម្រះនឹងស្តាប់ការសន្និដ្ឋានលើជំហរដើមបណ្តឹងរដ្ឋប្បវេណីក្នុងការសួរដេញដោលពីអត្តចរិកជនជាប់ចោទ ។ នៅថ្ងៃព្រហស្បតិ៍ សេចក្តីសម្រេចមួយលើកឡើងថា រយៈពេលសួរដេញដោលជនជាប់ចោទ ១ម៉ោង១៥នាទី សម្រាប់សហព្រះរាជអាជ្ញា និងមេធាវីការពារក្តី ។

នៅថ្ងៃដដែលនោះ ការឆ្លើយតបសំណួរសហព្រះរាជអាជ្ញាអន្តរជាតិ អង្គជំនុំជម្រះបានប្រកាសថា ការពិចារណា និងការជូនព័ត៌មានដល់ភាគីពាក់ព័ន្ធនឹងម៉ោងពេលកំណត់ក្នុងការសួរដេញដោលសាក្សីជំនាញ នៅសប្តាហ៍ក្រោយ ព្រមទាំងអត្តចរិកដែលសាក្សីជំនាញនឹងផ្តល់សក្ខីកម្ម ***ឧទា :*** តើគួរចូលរួមបញ្ចូលគ្នា ឬក៏ផ្តាច់ចេញពីគ្នា ។ ការហាមឃាត់ពីបញ្ហាកែសម្រួលម៉ោងពេលកំណត់ក្នុងដំណាក់កាលនេះ ដើម្បីពន្លឿនកិច្ចនីតិវិធី ប៉ុន្តែអនុញ្ញាតឱ្យដកចេញសាក្សីមួយចំនួន ដូចជា សាក្សី **D14** មេធាវីការពារក្តីដកពីបញ្ជីកោះហៅឱ្យផ្តល់សក្ខីកម្ម ។

***សហព្រះរាជអាជ្ញាស្នើសុំដាក់ចំពោះអង្គជំនុំជម្រះនូវឯកសារពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធ :*** នៅថ្ងៃច័ន្ទ សហព្រះរាជអាជ្ញាបានថ្លែងពីគោលបំណងដាក់ចំពោះមុខអង្គជំនុំជម្រះនូវឯកសារពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធ និងការស្នើសុំម៉ោងពេលកំណត់ក្នុងការដាក់ឯកសារនោះ ។ បន្ទាប់មក អង្គជំនុំជម្រះសម្រេចថា បញ្ហានេះគួរលើកឡើងនៅចុងបញ្ចប់នៃការសួរដេញដោលអំពីអត្តចរិកជនជាប់ចោទ ។ ការដាក់ជូនឯកសារថ្មី ស្ថិតក្រោមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ភាគីអាចធ្វើបាន ។

***ការកំណត់ទិសដៅនៃការបិទសវនាការសួរដេញដោល :*** ក្នុងការរៀបចំបិទសវនាការសួរដេញដោល អង្គជំនុំជម្រះបានឱ្យដឹងពី *"ទិសដៅសវនាការពាក់ព័ន្ធនឹងការទាមទារសំណង និងការដាក់សេចក្តីសន្និដ្ឋានបញ្ចប់"* ។ គួរកត់សម្គាល់ថា ការធ្វើសេចក្តីថ្លែងការណ៍ចុងក្រោយនឹងចាប់ផ្តើមនៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៩ ។

***វត្តមានភាគី :*** នៅថ្ងៃច័ន្ទ និងថ្ងៃអង្គារ លោក **William Smith** មានវត្តមានរួមជាមួយ លោក **សេង ប៊ុនខេង** និងលោក **Vincent de Wilde** តំណាងសហព្រះរាជអាជ្ញា ។ លោក **François Roux** លោកស្រី **Marie Paule Canizares** និងលោក **ការ សាវុត្ថ** តំណាងក្រុមមេធាវីការពារក្តី ។ នៅថ្ងៃពុធ លោក **William Smith** អវត្តមាន ។ នៅរសៀលថ្ងៃព្រហស្បតិ៍ សហព្រះរាជអាជ្ញាអន្តរជាតិលោក **Anees Ahmed** មានវត្តមានព្រមជាមួយលោក Vincent de Wilde និងលោក **សេង ប៊ុនខេង** ។

***វត្តមានសាធារណៈជន :*** ដោយសារការគាំទ្រពី អ.វ.ត.ក ប្រជាពលរដ្ឋប្រមាណជា ៥០០នាក់ ចូលរួមសវនាការនៅថ្ងៃច័ន្ទ ប្រហែលជា ៣០០នាក់ មកពីស្រុកបាកាន ខេត្តពោធិ៍សាត់ និង ២០០នាក់ទៀត មកពីស្រុកអមល័ង្គ ខេត្តកំពុងស្ពឺ ។ នៅថ្ងៃអង្គារ ប្រជាពលរដ្ឋប្រហែលជា ៤០០នាក់ មានវត្តមាន មកពីស្រុកស្ទោង ខេត្តកំពុងធំ សិស្សនិស្សិតប្រមាណជា ៧០នាក់ មកពីមហាវិទ្យាល័យន័រតុន និង ៣០នាក់ទៀត មកពី **YRDP** ព្រមទាំងប្រជាពលរដ្ឋ ២៦នាក់ មកពីខណ្ឌសែនសុខ រាជធានីភ្នំពេញ

ប៉ុន្តែប្រជាពលរដ្ឋភាគច្រើនចាក់ចេញពីសវនាការសាធារណៈមុនការបញ្ចប់ ។ នៅថ្ងៃពុធ ប្រជាពលរដ្ឋប្រហែលជា ៣០០នាក់ មកពីភូមិព្រៃខ្មែរ ស្រុកកំពុងត្រឡាច ខេត្តកំពុងចាម ។ នៅថ្ងៃប្រហស្បត្តិ៍ ប្រជាពលរដ្ឋប្រមាណជា ១៣០នាក់ មកពីខេត្តកំពុងចាម និង ១៤០នាក់ទៀត មកពីស្រុកបរិបូរណ៍ ខេត្តកំពុងឆ្នាំង ចូលរួមសវនាការ និងដើមបណ្តឹងរដ្ឋប្បវេណីមកពីសំណុំរឿងក្តីលេខ ០០២ ប្រមាណជា ៧០នាក់ ដោយការគាំទ្រពីអង្គភាពជន រងគ្រោះ ។

សំខាន់ជាងនេះ នៅថ្ងៃពុធ ប្រព័ន្ធផ្សព្វផ្សាយ អ.វ.ត.ក បានឱ្យដឹងថា មានអ្នកទស្សនាប្រមាណជា ២០.០០០នាក់ ។

## តារាងពេលវេលា :

| ថ្ងៃ- កាលបរិច្ឆេទ | ចាប់ផ្តើម | សំរាក- ព្រឹក | សម្រាក អាហារថ្ងៃត្រង់ | សម្រាក ពេលរសៀល | ម៉ោងបញ្ចប់ | សរុបចំនួនម៉ោង |
|---|---|---|---|---|---|---|
| ចន្ទ័ ២៤-០៨-០៩ | ០៩:០០ | ១០:៤៥-១១:១០ | ១១:៤៥-១៣:៣៨ | ១៤:៤០-១៥:០៥ | ១៦:៤០ | ៤ ម៉ ៥៧ នាទី |
| អង្គារ ២៥-០៨-០៩ | ០៩:០៧ | ១០:៤០-១១:០៥ | ១២:២៥-១៣:៤០ | ១៤:៤៥-១៥:២៥ | ១៥:៤៥ | ៤ ម៉ ១៨ នាទី |
| ពុធ ២៦-០៨-០៩ | ០៩:០៥ | ១០:២០-១០:៥០ | ១២:០៥ | - | - | ២ ម៉ ៣០ នាទី |
| ព្រហស្បត្តិ៍ ២៧-០៨-០៩ | ០៩:១០ | ១០:៤០-១១:០៧ | ១២:០៦-១៣:៣៥ | ១៤:០២- ១៥:០០ | ១៦:៣៣ | ៤ ម៉ ២៩ នាទី |

ចំនួនម៉ោងជាមធ្យម : ៤ ម៉ ០៣ នាទី

ចំនួនម៉ោងសរុបនាសប្តាហ៍នេះ : ១៦ ម៉ ១៤ នាទី

ចំនួនសរុប ម៉ោង ថ្ងៃ និង សប្តាហ៍ នៅសវនាការ : ២៨៨ ម៉ ៥៤ នាទី នៃ ៦៥ ថ្ងៃសវនាការ នៃសប្តាហ៍ទី ១៨

---

**អំពីកម្មវិធីអ្នកឃ្លាំមើលតុលាការកាត់ទោសខ្មែរក្រហម** (“កម្មវិធី”) : ជាកម្មវិធីរបស់អង្គការ the Asian International Justice Initiative (AIJI) ដែលជាកិច្ចសហការណ៍រវាង U.C. Berkeley War Crimes Studies Center និង East-West Center ។

កម្មវិធីនេះចេញរបាយការណ៍ប្រចាំសប្តាហ៍ អំពីកិច្ចដំណើរការនីតិវិធីសវនាការនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ឬតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ បច្ចុប្បន្ន កម្មវិធីនេះកំពុងតែឃ្លាំមើលដំណើរការនៃការកាត់ទោសលើសំណុំរឿង **កាំង ហ្កិចអ៊ាវ** ហៅ **ឌុច** ដែលជារឿងក្តីដំបូងឈានដល់ដំណាក់កាលជំនុំជម្រះ ។

របាយការណ៍ប្រចាំសប្តាហ៍នេះ ត្រូវបានរៀបចំដោយក្រុមឃ្លាំមើលតុលាការ ដែលដឹកនាំដោយលោកស្រី **Michelle Staggs** ជានាយិការងនៃអង្គការ AIJI ដែលមានសមាសភាពដូចខាងក្រោម :

**ក្រុមទី១**
- លោកស្រី **ជូ វិនាថ** : ប្រធានកម្មវិធីសង្កេតការណ៍តុលាការនៃ CSD
- លោក **ង៉ែត សុវណ្ណនិត** : បុគ្គលិកអង្គការ KID
- កញ្ញា **Yvette Anthony** : សិង្ហបុរី
- លោក **Florian Hansen** : អាល្លឺម៉ង់
- កញ្ញា **Caroline Ehlert Zurich** : ស្វីស
- កញ្ញា **Deepika Sharma** : សហរដ្ឋអាមេរិក

**ក្រុមទី២**
- កញ្ញា **សេក សុវណ្ណា** : មេធាវី អង្គការ CLEC
- លោក **ភ័ក្រ្ត សាវ៉ន** : បុគ្គលិកអង្គការ UNOHCHR
- កញ្ញា **Aviva Nababan** : ឥណ្ឌូនេស៊ី
- កញ្ញា **Romana Weber** : ស្វីស
- កញ្ញា **Binxin Zhang** : ចិន
- លោក **Jaspreet Dosanjh** : សហរដ្ឋអាមេរិក

កម្មវិធីនេះ បានសហការជាមួយមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម (CSD) និង (KID) ដើម្បីផ្សព្វផ្សាយរបាយការណ៍នេះ ។ លោក-អ្នកអាចរកបាននូវរបាយការណ៍នេះជាភាសាខ្មែរ និងអង់គ្លេស នៅក្នុង www.csdcambodia.org ; www.kidcambodia.org និង http://Socrates.berkeley.edu/-warcrime/ ។